# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៣-៤ ខែកក្កដា ឆ្នាំ២០១០ខាងមុខនេះ សហគមន៍ខ្មែរកម្ពុជាក្រោមមានរៀបចំមហាសន្និបាតនៅទីក្រុងតូរ៉ុនតូ ប្រទេសកាណាដា ដើម្បីប្រមូលយកយោបល់សំខាន់ៗពីគ្រប់មជ្ឈដ្ឋាន ដោយមិនប្រកាន់និន្នាការនយោបាយ និងសាសនាឡើយ។ មហាសន្និបាតមានការអញ្ជើញដោយ ឯកឧត្តម ថាច់ សេដ្ឋា នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម ក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាអតីតសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

សហគមន៍ខ្មែរកម្ពុជាក្រោម មានកិត្តិយសសូមគោរពនិមន្តនិងអញ្ជើញ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា សិស្ស និស្សិតទាំងអស់ ដែលស្រឡាញ់ទឹកដីកម្ពុជាក្រោម អាណិតអាសូរ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម សូមព្រះមេត្តានិងមេត្តា និមន្តនិងអញ្ជើញចូលរួមឲ្យបានច្រើន ដើម្បីផ្តល់ជាយោបល់និងបទពិសោធន៍ដល់យើងខ្ញុំព្រះករុណា យើងខ្ញុំ។

ទស្សនទាន និងបទពិសោធន៍របស់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា សិស្ស និស្សិតទាំងអស់ យើងខ្ញុំព្រះករុណា យើងខ្ញុំនឹងរៀបចំជាយុទ្ធសាស្ត្រសំរាប់អនុវត្តក្នុងការតស៊ូទាមទារសិទ្ធិសេរីភាពជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោម។

ការរួមគំនិត រួមយោបល់និងសាមគ្គីជាធ្លុងមួយ គឺជាកម្លាំងចលករតែមួយគត់ ដែលនាំមកនូវជ័យជំនះដ៏មានប្រសិទ្ធភាព និងឆាប់បំផុត។ មានតែកត្តារួបរួមសាមគ្គីជាធ្លុងមួយនេះទេ ដែលអាចជួយស្រោចស្រង់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ឲ្យរួចផុតពីការរលាយពូជសាសន៍ និងសាសនាបាន។

ទីកន្លែង និងពេលវេលា: 25 Galsworthy Avenue, Scarborough, Ontario M1R 2N5 Canada ។

យើងខ្ញុំព្រះករុណា យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា សិស្ស និស្សិតទាំងអស់ ដែលកំពុងខ្វល់ខ្វាយយ៉ាងអន្ទះសាចំពោះសុខទុក្ខប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ពិតជាលះបង់ពេលវេលាដ៏មានតម្លៃនិមន្តនិងអញ្ជើញចូលរួមជាក់ជាមិនខាន។

*ក្រុងហ្វីឡាដេលហ្វីយ៉ា សហរដ្ឋអាមេរិក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០*

*សូមទាក់ទង:*

- ៩៧៨.៣២៨.៤៤៣៥
- ៤១៦.៧២០.០៨៤២
- ២៦៧.២៤២.៣៦០៨
- ៤០១.៦៩៩.៩៣២០

សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង
អគ្គលេខាធិការដ្ឋាន

E-Mail: kkcpressoffice@yahoo.com, KKC website: www.khmerkromngo.org

សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTĖ DU KHMER KAMPUCHEA KROM

# Press Release

*For Immediate Release*
Philadelphia, United States of America June 24, 2010

The Khmer Kampuchea Krom Community (KKC) has an honor to cordially invite you, the eminent venerable Buddhist monks, compatriots, youth and students, inclusive and non-discrimination to political affiliations and religions, to participate in its convention with the Honorable Thach Setha, KKC Executive Director, Phnom Penh Councilman, and former Senator of Cambodia, in Toronto city, Canada.

Date: July 3 – 4, 2010

Venue: 25 Galsworthy Avenue, Scarborough, Ontario, M1R 2N5 Canada.

The Secretariat
KKC-North America

Contact information:
- 978.328.4435
- 416.720.0842
- 267.242.3608
- 401.699.5320